ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍អាងទឹកកែប្រៃ
# រយៈពេល ៣ឆ្នាំ ២០១៩- ឆ្នាំ២០២២

ឈ្មោះសហគមន៍នេសាទ ៖ **អាងទឹកកែប្រៃ**

ភូមិ ៖ ល្អាក

ឃុំ ៖ ស្រក

ស្រុក ៖ កំពង់សៀម

ខេត្ត ៖ កំពង់ចាម



ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍អាងទឹកកែប្រែ

# រយៈពេល ៣ឆ្នាំ ២០១៩- ឆ្នាំ២០២២

| | |
|---|---|
| ឈ្មោះសហគមន៍នេសាទ | ៖ **អាងទឹកកែប្រែ** |
| ភូមិ | ៖ ល្អាក |
| ឃុំ | ៖ ស្រក |
| ស្រុក | ៖ កំពង់សៀម |
| ខេត្ត | ៖ កំពង់ចាម |

## មាតិកា
## ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍


**១- ស្ថានភាពទូទៅ**

**២- អំពីប្រជាសាស្ត្រ**

ក- ប្រជាពលរដ្ឋ..........១

ខ- មុខរបរ..........២

**៣- កន្លែងនេសាទសហគមន៍ និងធនធានដែលមាននៅក្នុងកន្លែងនេសាទសហគមន៍**

ក- ទីតាំង..........២

ខ- ដែននេសាទ..........២

គ- តំបន់ដែលមានលទ្ធភាពបង្កើតកន្លែងអភិរក្ស..........២

ឃ- ធនធានជលផល..........២

**៤- ការធ្វើនេសាទ**

ក- អ្នកនេសាទ..........៣

ខ- ឧបករណ៍នេសាទ..........៣

គ- ការប៉ាន់ប្រមាណផលចាប់ប្រចាំឆ្នាំ..........៤

**៥- ផែនការគ្រប់គ្រងសហគមន៍នេសាទ**

ក- ទស្សនៈវិស័យ..........៥

ខ- គោលបំណង..........៥

គ- ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

គ១- ផែនការប្រើប្រាស់ឧបករណ៍នេសាទ..........៥

គ២- ផែនការកែលំអដែននេសាទ..........៦

គ៣- ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស..........៦

គ៤- ផែនការគ្រប់គ្រងព្រៃលិចទឹក..........៧

គ៥- ផែនការទប់ស្កាត់បទល្មើសនេសាទ..........៧

គ៦- ផែនការប្រជុំប្រចាំខែ និងសម្ភារៈអនុវត្តការងាររបស់គណៈកម្មការសហគមន៍នេសាទ..........៨

គ៧- ផែនការផ្សព្វផ្សាយនិងបណ្តុះបណ្តាល..........៨

គ៨- ផែនការវារីវប្បកម្ម..........៩

គ៩- ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍសហគមន៍..........៩

ឃ. ផែនការយុទ្ធសាស្ត្រ..........១០

\- តារាងសង្ខេបផែនការ..........១២

\- តារាងកម្មវិធីការងារ..........១៤

# ផែនការគ្រប់គ្រង
# កន្លែងនេសាទសហគមន៍

## ១ ស្ថានភាពទូទៅ

សហគមន៍នេសាទអាងទឹកកែប្រែ ត្រូវបានបង្កើតឡើងដោយមហាសន្និបាតកំណើតដំបូងនៅ ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៦ និងបានធ្វើកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៨ ។

សហគមន៍នេសាទអាងទឹកកែប្រែ មានទីតាំងស្ថិតនៅភូមិល្អាក ឃុំស្រក ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ ដែលមានសមាជិកសរុបចំនួន១៣៣នាក់ ប្រុស៨១នាក់ ស្រី៥២នាក់ និងមានគណៈកម្មការចំនួន០៩នាក់ ស្ត្រីចំនួន០១នាក់។

កន្លងមកសហគមន៍នេសាទនេះបានដំណើរការសកម្មភាពសំខាន់ៗរបស់ខ្លួនរួមមាន ៖

- បោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទ
- រៀបចំបញ្ជីឈ្មោះសមាជិក និងគណៈកម្មការ សហគមន៍នេសាទ
- រៀបចំរចនាសម្ព័ន្ធគណៈកម្មការ សហគមន៍នេសាទ
- រៀបចំលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ
- រៀបចំកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍
- កំណត់ព្រំប្រទល់កន្លែងនេសាទសហគមន៍ និងធ្វើផែនទី
- ចុះបញ្ជីនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានរៀបចំធនាគារស្រូវ

## ២ អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម

### ក. ប្រជាសាស្ត្រ

- ចំនួនប្រជាពលរដ្ឋសរុបក្នុងតំបន់មាន២៧៥៧នាក់ ប្រុស១៣៤៦នាក់ ស្រី១៤១១នាក់ ក្នុងនោះ មានចំនួន ៧០៣គ្រួសារ ។
- ប្រជាពលរដ្ឋក្នុងសហគមន៍ជាអ្នកកាន់សាសនាព្រះពុទ្ធ១០០%។
  ក្នុងចំណោមសមាជិកគ្រួសារនៃសមាជិកសហគមន៍នេសាទទាំងអស់ អ្នកមិនចេះអក្សរចំនួន២៧នាក់ ស្រី០៩នាក់ កម្រិតថ្នាក់បឋមសិក្សាចំនួន១២២នាក់ ស្រី៣៥នាក់ កម្រិតមធ្យមសិក្សាចំនួន ៨១នាក់ ស្រី១៥នាក់ និងកម្រិតឧត្តមសិក្សាចំនួន១៥នាក់ ស្រីចំនួន១នាក់។
- ចំនួនស្ត្រីមេម៉ាយក្នុងសហគមន៍នេសាទមានប្រហែល ១០នាក់
- ចំនួនជនពិការក្នុងសហគមន៍នេសាទមាន ៣២នាក់ ស្រី០នាក់
- ចំនួនចាស់ជរាក្នុងសហគមន៍នេសាទមាន ០ នាក់ ស្រី០នាក់
- ចំនួនកុមារកំព្រាក្នុងសហគមន៍នេសាទមាន០៨នាក់ ស្រី០២នាក់
- ចំនួនអ្នកមានជំងឺរ៉ាំរ៉ៃក្នុងសហគមន៍នេសាទមាន០នាក់ ស្រី០នាក់។

### ខ. មុខរបរ

មុខរបរសំខាន់ៗរបស់សមាជិកក្នុងសហគមន៍នេះរួមមាន៖

- ធ្វើនេសាទចំនួន៧១៤ គ្រួសារ
- ធ្វើស្រែចំនួន១៥១៧ គ្រួសារ ទំហំ១៤៦៧ហិកតា
- ធ្វើវារីវប្បកម្មចំនួន ៣៦គ្រួសារ ស្រះចំនួន៥ស្រះ ទំហំ ០,៣៧ហិកតា បៃត្រីចំនួន៥
- ដាំបន្លែចំនួន ០គ្រួសារ ទំហំ០ហិកតា
- ជាងផ្ទះចំនួន ៤គ្រួសារ
- លក់ដូរចំនួន០៣ គ្រួសារ
- ចំការ ១០គ្រួសារ
- ប្រាក់ចំណូលជាមធ្យមក្នុង០១គ្រួសារប្រចាំឆ្នាំមានចំនួន ៦ ០០០ ០០០រៀល ។

## ៣ កន្លែងនេសាទសហគមន៍ និងធនធានដែលមាននៅក្នុងនេសាទសហគមន៍

### ក. ទីតាំង

កន្លែងនេសាទសហគមន៍អាងទឹកកែប្រែ ជាអាងស្តុកទឹកមួយដែលបានសាងសង់ឡើងនាសម័យប៉ុលពតសម្រាប់ស្រោចស្រពដំណាំ និងស្រែចំការនៅជុំវិញតំបន់នោះ ។ អាងនេះត្រូវបានរៀបចំកែលំអរឡើងវិញ និងកំណត់ទីតាំងជាក់លាក់នៅឆ្នាំ១៩៩៦ ដែលមានផ្ទៃដីទំហំ **១២០**ហិកតា និងមានកំណត់និយាមកាដូចមានចែងនៅក្នុងកិច្ចព្រមព្រៀង ។

មានព្រំប្រទល់ ៖

- ខាងជើងទល់នឹង ៖ ចំការរបស់កសិករ តែម ខុម ថាំ ចុល យឹន គីម សុខ ប៉ុន អិត កន និងកសិករ សរ ផ្លូច
- ខាងត្បូងទល់នឹង ៖ ចំការ របស់កសិករ ទ្រាន់ ស៊ុយ ជរ សៀវ ព្រិច ណា ហេង ផៃលីម ឆេង ឈឿន ស៊ិន សែរ និងកសិករ គាម ព្រាន
- ខាងកើតទល់នឹង ៖ ផ្លូវលំ១៥ម៉ែត្រ (ខ្នងទំនប់) របស់ភូមិល្អាក
- ខាងលិចទល់នឹង ៖ ចំការរបស់កសិករ អ៊ូច និល ផុន ចុល ផុន រ៉េន ពុធ មេន និងកសិករ នន មៀច

### ខ. ដែននេសាទ

កន្លែងនេសាទសហគមន៍នេសាទអាងទឹកកែប្រែ ពុំមានបឹង ឬព្រែកទេ ព្រោះជាទំនប់បង្ងៀរទឹកដែលមានទ្វារទឹកសម្រាប់បើកបិទតែប៉ុណ្ណោះ

### គ. តំបន់ដែលមានលទ្ធភាពបង្កើតកន្លែងអភិរក្ស

- តាមបណ្តោយអាងទឹក ទំហំ (២០០មx២០០ម)

### ឃ. ធនធានជលផល

- ប្រភេទត្រី ៖

ត្រីរ៉ស់ ត្រីប្រា ត្រីឆ្តោរ ត្រីឆ្លាំង ត្រីកែស ត្រីឆ្តោក ត្រីក្អែក ត្រីក្រសក់ ត្រីកញ្ចុះ ត្រីលិញ ត្រីរៀល ត្រីក្រាញ់ ត្រីចង្វារ ត្រីផ្ទោង ត្រីស្លូញ ត្រីពោ ត្រីអាចម៍កុក ត្រីស្លឹកឬស្សី ត្រីកន្ទ្រប់ ក្តាំងហាយ ត្រីខ្នាន់ ត្រីក្រឡង់ ត្រីសណ្តាយ ត្រីអណ្តែង ត្រីដំរី ត្រីតាអោន ត្រីក្រម៉ម ត្រីស្លាត ត្រីកំភ្លៀវ ត្រីខ្នឹង ត្រីអំពិលទុំ ត្រីគ្រុំ ត្រីផ្កាស្មៅ ត្រីឈ្មៀត ត្រីកញ្ជូក ត្រីបណ្តូលអំពៅ ត្រីប្រកែង ត្រីកាហែ ត្រីក្រឹម ត្រីក្រឹមទន្សាយ ត្រីស្រកាក្តាម ត្រីលលកសរ ត្រីឆ្ពិន ត្រីជញ្ជក់ ត្រីបណ្តូលចេក ត្រីព្រលូង ត្រីកំពត ត្រីក្រពាត់ ត្រីក្រុស ត្រីកញ្ជាញ់ច្រាស ត្រីកំភ្លាញ ត្រីស្លាត ត្រីក្រាយ ត្រីអណ្តាតឆ្កែ កំពិស បង្កង។

- **ប្រភេទវារីសត្វ ៖**

អណ្តើក ពស់ ខ្យងគូចស្រួច ខ្យងគូចទាល ខ្យងមាស( ខ្យងពណ៌លឿង ) ក្តាម អន្ទង់ ខ្ចៅគូចស្រួច ខ្ចៅគូចទាល កង្កែប ឈ្លើង គ្រុំ គ្រុំចំពុះទា លៀស ។ល។

- **ប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារីរុក្ខជាតិ ៖**

ដើមឬថ្លើមអណ្តើក ខ្លបយក្ស(អួយយ៉ាស់/បន្លាយយួន) រាំង ប្របួយមេ ប្របួយឈ្មោល ស្បាត ភ្នំភ្លែង អញ្ចាញ ត្នូ កន្ទ្រៀង ស្លែងក្របី ធ្មេញត្រីញី ទៀនព្រៃ ត្រស់ ថ្ងាង ត្នូ ខ្នាយមាន់ វល្លិ៍ប្រេង វល្លិ៍ទឹកដោះ វល្លិ៍ត្រដិត វល្លិ៍ដោះគន់ វល្លិ៍ត្រីវល្លិ៍ត្អើក ល្ពាក់ទឹក ស្លាបទា កន្ទាំងហៃ ស្មោ ស្លួត បន្លាឃ្លេ ថ្ងាន់ ស្នូលទឹក ច្រកែង ប្រផេញ ផ្តៅ ភ្នែកព្រាប វល្លិ៍អណ្តាតត្រកួត ក្រចាប់ សារាយសាប កំប្លោក ចកតូច ចកធំ កំពីងពួយស កំពីងពួយក្រហម ត្រកួន ព្រលិតអាចមន៍មាន់ ព្រលិតដូង រំចង់ ស្លន់អំបោះ ត្រាវអណ្តែត ស្មៅអន្ទក់ទឹក ស្មៅអំពៅខៀប ចំបូង កក់ជ្រុង កក់ក្តាម ឈូក ចន្ទល់ភ្នំ(វល្លិ៍ថ្កាល់ត្រី) កញ្ឆែត ស្មៅថ្នក់ទឹក ។ល។ ( សូមជួយមើល និងកែទីនេះផង)

## ៤. ការធ្វើនេសាទ

### ក. អ្នកនេសាទ ៖

- អ្នកនេសាទជាសមាជិកសហគមន៍នេសាទមានចំនួន ៨២នាក់ ស្រី ១៣នាក់
- ប៉ាន់ស្មានអ្នកនេសាទមិនមែនជាសមាជិកសហគមន៍នេសាទនៅក្នុងសហគមន៍មានចំនួន១៣៥នាក់ ស្រី០៧នាក់
- ប៉ាន់ស្មានអ្នកនេសាទមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍មានចំនួន៦៦នាក់ ស្រី០៣នាក់

### ខ. ឧបករណ៍នេសាទ ៖

- ឧបករណ៍នេសាទ និងទូកកាណូតរបស់សមាជិកសហគមន៍នេសាទ ៖

| ប្រភេទឧបករណ៍ | ឯកតា | ចំនួនគ្រួសារ | ចំនួនឧបករណ៍នេសាទ | ទំហំ/ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ (ខែ....ដល់ខែ....) |
|---|---|---|---|---|---|
| មងពាក់ | ម៉ែត្រ | ៨០ | ១០០០គ្រួសារ | ៨០ ០០០ម | ពេញមួយឆ្នាំ |
| សន្ទូចរនង | ផ្លែ | ៥០ | ៥០០ផ្លែ/គ្រួសារ | ២៥.០០០ផ្លែ | ពេញមួយឆ្នាំ |
| លបត្រី | គ្រឿង | ២០ | ២០គ្រឿង/គ្រួសារ | ៤០០គ្រឿង | ពេញមួយឆ្នាំ |
| បបក់ | គ្រឿង | ១០ | ១គ្រឿង/គ្រួសារ | ១០គ្រឿង | ពេញមួយឆ្នាំ |
| ឆក់ក្តៅ | គ្រឿង | ១០ | ១គ្រឿង/គ្រួសារ | ១០គ្រឿង | ពេញមួយឆ្នាំ |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| ទូកមានម៉ាស៊ីន | 0 | 0 | 0 |
| ទូកអុំ និងចែវ | ៤០គ្រឿង | ១៥០-២០០ គីឡូក្រាម | ៣៣ សេះ |

- ឧបករណ៍នេសាទនិងទូកកាណូតរបស់អ្នកនៅក្នុងតំបន់ប៉ុន្តែមិនមែនជាសមាជិកសហគមន៍នេសាទ ៖

| ប្រភេទឧបករណ៍ | ឯកតា | ចំនួនគ្រួសារ | ចំនួនឧបករណ៍នេសាទ | ទំហំ/ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ (ខែ....ដល់ខែ....) |
|---|---|---|---|---|---|
| មងពាក់ | ម | ២០ | ១២០០ម/គ្រួសារ | ២៤ ០០០ម | ពេញមួយឆ្នាំ |
| សន្ទូចរនង | ផ្លែ | ៣៥ | ៣៣០ផ្លែ/គ្រួសារ | ១១ ៥៥០ផ្លែ | ពេញមួយឆ្នាំ |
| លបត្រី | គ្រឿង | ២០ | ១០គ្រឿង/គ្រួសារ | ២០០គ្រឿង | ពេញមួយឆ្នាំ |
| សំណាញ់ | វង់ | ១០ | ១វង់/គ្រួសារ | ១០វង់ | ពេញមួយឆ្នាំ |
| ឆក់ក្តៅ | គ្រឿង | ១០ | ១គ្រឿង/គ្រួសារ | ១០គ្រឿង | ពេញមួយឆ្នាំ |
| បបក់ | គ្រឿង | ២០ | ១គ្រឿង/គ្រួសារ | ២០គ្រឿង | ពេញមួយឆ្នាំ |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| ទូកមានម៉ាស៊ីន | ០៥គ្រឿង | ១៥០-២០០គីឡូក្រាម | ធំជាង ៣៣សេះ |
| ទូកអុំ និងចែវ | ១០គ្រឿង | ១៥០-២០០ គីឡូក្រាម | ៣៣សេះ |

- ឧបករណ៍នេសាទ និងទូកកាណូតរបស់អ្នកមិនមែនជាសមាជិកសហគមន៍ដែលមកពីខាងក្រៅសហគមន៍ៈ

| ប្រភេទឧបករណ៍ | ឯកតា | ចំនួនគ្រួសារ | ចំនួនឧបករណ៍នេសាទ | ទំហំ/ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ (ខែ....ដល់ខែ....) |
|---|---|---|---|---|---|
| មងពាក់ | ក្បួង | ២០ | ២០០ម/គ្រួសារ | ៤០០០ម | ពេញមួយឆ្នាំ |
| សន្ទូចរនង | ផ្លែ | ១៥ | ៥០០ផ្លែ/គ្រួសារ | ៧.៥០០ផ្លែ | ពេញមួយឆ្នាំ |
| សន្ទូចបង្កៃ | ផ្លែ | ១០ | ៥០ផ្លែ/គ្រួសារ | ៥០០ផ្លែ | ពេញមួយឆ្នាំ |
| ឆក់ | គ្រឿង | ២០ | ១គ្រឿង/គ្រួសារ | ១០គ្រឿង | ពេញមួយឆ្នាំ |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| ទូកមានម៉ាស៊ីន | 0 | 0 | 0 |
| ទូកចែវ ឬទូកគ្មានម៉ាស៊ីន | 0 | 0 | 0 |

គ. ការប៉ាន់ប្រមាណផលចាប់បានប្រចាំឆ្នាំ

| ប្រភេទផលនេសាទ | បរិមាណផលនេសាទចាប់បានគិតជាមធ្យមប្រចាំគ្រួសារ (គិតជា គក) | | |
|---|---|---|---|
| | រដូវប្រាំង | រដូវវស្សា | សរុបប្រចាំឆ្នាំ |
| ត្រី ចំរុះ | ៩១០គីឡូក្រាម | ៣៩៤០គីឡូក្រាម | ៤៨៥០គីឡូក្រាម |
| ខ្យង និងលៀស | ៥០០គីឡូក្រាម | ៥០០គីឡូក្រាម | ១០០០ គីឡូក្រាម |

## ៥-ផែនការគ្រប់គ្រងសហគមន៍នេសាទ

ក. ទស្សនៈវិស័យ ៖

សហគមន៍នេសាទអាងទឹកកែប្រែ មានទស្សនៈវិស័យចូលរួមចំណែកគ្រប់គ្រងធនធានជលផលប្រកបដោយសមធម៌និងចីរភាព ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ។

**ខ. គោលបំណង ៖**

- ចូលរួមគ្រប់គ្រងដែននេសាទទឹកសាបដែលបានលុបពីឡូត៍នេសាទ កន្លែងនេសាទគ្រួសារដែលរក្សាទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាប្រពៃណី ឬសហគមន៍ធ្វើនេសាទ កន្លែងនេសាទបំរុង ទំនាបលិចទឹក ក្នុងរដូវតំឡើង នាទីព្រៃលិចទឹក ។
- ចូលរួមគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តភាព និងធានាការបែងចែកផលប្រយោជន៍ ធនធានជលផលជូនប្រជាពលរដ្ឋខ្មែរប្រកបដោយសមធម៌ ។
- ដើម្បីធ្វើឱ្យប្រសើរឡើងនូវជីវភាពសមាជិកសហគមន៍ តាមរយៈការអភិវឌ្ឍន៍ចម្រុះដោយមានការចូលរួម ។
- ដើម្បីឱ្យប្រជាពលរដ្ឋខ្មែរបានយល់ច្បាស់ ហើយនិងឈានទៅចាត់ទុកថាខ្លួនជាម្ចាស់លើធនធានធម្មជាតិ ។

**គ. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍**

**គ.១ ផែនការប្រើប្រាស់ឧបករណ៍នេសាទ**

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ គឺរៀបចំឡើងដោយគិតគូរអំពីប្រភេទដែននេសាទ ប្រភេទ ទំហំ ប្រវែង និងចំនួនឧបករណ៍នេសាទ ចំនួនអ្នកនេសាទ និងរដូវនេសាទ ។

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ត្រូវបានរៀបចំឡើងដូចខាងក្រោម ៖

| ឈ្មោះ/ទីតាំងកន្លែងនេសាទ | ពេលវេលាធ្វើនេសាទ | ឧបករណ៍នេសាទអនុញ្ញាតឱ្យប្រើ | | | ផ្សេងៗ |
|---|---|---|---|---|---|
| | | ប្រភេទ | ទំហំ/ប្រវែង | ចំនួន | |
| អាងទឹកកែប្រែ | ខែតុលា ដល់ ឧសភា | មង | ១០០ម/គ្រួសារ | ១០គ្រួសារ | សមាជិកសហគមន៍ អ្នកនេសាទខាងក្នុង និង អ្នកនេសាទខាងក្រៅ |
| | ខែកក្កដា ដល់ ខែវិច្ឆិកា | សន្ទូចរនង | ១០០ផ្លែ/គ្រួសារ | ១០គ្រួសារ | សមាជិកសហគមន៍ អ្នកនេសាទខាងក្នុង និង អ្នកនេសាទខាងក្រៅ |
| | ពេញមួយឆ្នាំ | សន្ទូចបង្កៃ | ៥០ផ្លែ/គ្រួសារ | ៥គ្រួសារ | សមាជិកសហគមន៍ អ្នកនេសាទខាងក្នុង និង អ្នកនេសាទខាងក្រៅ |
| | ពេញមួយឆ្នាំ | សំណាញ់ | ១គ្រឿង/គ្រួសារ | ៥គ្រួសារ | សមាជិកសហគមន៍ អ្នកនេសាទខាងក្នុង និង អ្នកនេសាទខាងក្រៅ |
| | ពេញមួយឆ្នាំ | ទ្រូ | មិនកំណត់ | មិនកំណត់ | សមាជិកសហគមន៍ អ្នកនេសាទខាងក្នុង និង អ្នកនេសាទខាងក្រៅ |
| | ពេញមួយឆ្នាំ | បបក់ | ១គ្រឿង/គ្រួសារ | ៦គ្រួសារ | សមាជិកសហគមន៍ អ្នកនេសាទខាងក្នុង និង |

| | | | | | |
|---|---|---|---|---|---|
| | | | | | អ្នកនេសាទខាងក្រៅ |

### គ.២ ផែនការកែលំអដែននេសាទ

ផែនការកែលំអដែននេសាទត្រូវបានរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោម៖

| ដែននេសាទ | ទំហំ | ទំហំដែលត្រូវកែលំអ | សកម្មភាព | ថវិកាប៉ាន់ប្រមាណតម្លៃ(ដុល្លា) | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្ដើម - បញ្ចប់ |
|---|---|---|---|---|---|
| អាងទឹកកែប្រែ | ០,៥ហិកតា | ៥០មx១០០មx៣ម | គ្រឿងចក្រស្តារឡើងវិញ ឬ ម៉ាស៊ីនបូមដី | ៥ ០០០ | ២០១៩ - ២០២១ |
| | | | ស្វែងរកម្ចាស់ជំនួយ | ៣០០ | ២០១៩ - ២០២០ |
| | | | ប្រជុំផ្សព្វផ្សាយ | ៥០០ | ២០១៩ - ២០២១ |
| | ១០ហិកតា | ១០ហិកតា | -ស្រង់ឈ្មោះម្ចាស់ដីដែលធ្វើចំការក្នុងដែនស.ន<br>-អប់រំណែនាំ និងធ្វើកិច្ចសន្យាបញ្ឈប់ការទន្ទ្រានដី<br>-ធ្វើការជាកពិន័យករណីមិនរាងចាល | | ២០១៩-២០២២ |

### គ.៣ ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស

ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស នឹងត្រូវរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោម៖

| ឈ្មោះដែននេសាទ | ទំហំ (ហ.ត) | ប្រភេទនៃការអភិរក្ស | សកម្មភាព | ប៉ាន់ប្រមាណតម្លៃ(ដុល្លា) | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្ដើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|---|
| អាងទឹកកែប្រែ | ០,៥ហិកតា | ត្រីមេពូជ | ផ្សព្វផ្សាយពីកន្លែងអភិរក្ស និងការហាមឃាត់ដល់ប្រជាពលរដ្ឋឱ្យបានទូលំទូលាយ ២ដង/ឆ្នាំ | ៣០០ | ២០១៩ | ២០២១ |
| | | | បោះបង្គោលព្រំតំបន់អភិរក្ស ចំនួន៨បង្គោល | ១ ៥០០ | មេសា/២០២០ | ឧសភា/២០២១ |
| | | | ដាក់ស្លាកសញ្ញាចំនួន១ និងតូច ៨ស្លាក | ៣០០ | ឧសភា/២០២០ | |

| | | | | | | |
|---|---|---|---|---|---|---|
| | | | ល្បាតការពារជាប្រចាំកន្លែងអភិរក្ស(២ដង/ខែ) | ១ ៦២០ | កក្កដា២០១៩ | មិថុនា ២០២២ |
| | | | លែងកូនត្រីចំរុះ និងពូជខ្យង ៣ដង | ១៥០០០ | កក្កដា២០១៩ | មិថុនា ២០២២ |

## គ.៤ ផែនការគ្រប់គ្រងព្រៃលិចទឹក

ផែនការគ្រប់គ្រងព្រៃលិចទឹកត្រូវបានរៀបចំឡើង ដូចមាននៅក្នុងតារាងខាងក្រោម៖

| ឈ្មោះដែននេសាទ | ទំហំ (ហ.ត) | ប្រភេទព្រៃឈើការពារ | សកម្មភាព | ប៉ាន់ប្រមាណតម្លៃ(ដុល្លា) | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|---|
| ជុំវិញអាងទឹកកែប្រែ | ១០ហិកតា | ត្រស់ តាអូរ ឬស្សី | ផ្សព្វផ្សាយពីកន្លែងព្រៃលិចទឹកឱ្យបានទូលំទូលាយ | ៦០០ | សីហា / ២០១៩ | មេសា /២០២២ |
| | | | ដាំព្រៃលិចទឹកចំនួន៨.០០០ដើម | ៨០០០ | ឧសភា/២០២០ | ឧសភា/២០២២ |

## គ៥-ផែនការទប់ស្កាត់បទល្មើសជលផល

ផែនការចុះទប់ស្កាត់បទល្មើសជលផលត្រូវបានរៀបចំដូចខាងក្រោម:

| សកម្មភាព | លទ្ធផលរំពឹងទុក | ប៉ាន់ប្រមាណតម្លៃ(ដុល្លា) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ប្រជុំផ្សព្វផ្សាយ | -មានការយល់ដឹងពីការប្រើប្រាស់ឧបករណ៍នេសាទ<br>-ការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ថយចុះ | ១ ២០០ | គណៈកម្មការសមាជិកស.នអាជ្ញាធរមូលដ្ឋាន ជំនាញ | មិនា និងមិថុនា/រៀងរាល់ឆ្នាំ (៣ឆ្នាំ) | |
| ប្រជុំពិភាក្សាគណៈកម្មការសហគមន៍រៀបចំផែនការប្រចាំឆមាស | -គណៈកម្មការទទួលបាននូវបទពិសោធន៍ល្អៗ<br>-មានផែនការសមស្របជាក់លាក់ដើម្បីចុះអនុវត្ត ការងារ | ១២០ (២ដង/ឆ្នាំ) | គណៈកម្មការសមាជិកស.នអាជ្ញាធរមូលដ្ឋាន អង្គភាពពាក់ព័ន្ធ | មករា និងមិថុនា/រៀងរាល់ឆ្នាំ(៣ឆ្នាំ) | |
| អនុវត្តផែនការ៖ (រៀបចំកំលាំងចុះបង្ក្រាបដល់ទីកន្លែងដោយទំនាក់ទំនង និង សហការជាមួយអាជ្ញា | -បទល្មើសនេសាទថយចុះ និងឈានទៅលុបបំបាត់ទាំងស្រុង<br>-ធនធានជលផលកើនឡើង<br>-ជីវភាពសមាជិកស.នធូរជារ | ៣ ៦០០ (៥០/ដង) | គណៈកម្មការសមាជិកស.នអាជ្ញាធរមូលដ្ឋានជំនាញជលផល | (២ដង/ខែ) ជាប្រចាំ (រយៈពេលបីឆ្នាំ) | |

| | | | | |
|---|---|---|---|---|
| ធរមូល ដ្ឋាន<br>និងអង្គភាពពាក់ព័ន្ធ ) | | | | |

## គ៦-ផែនការប្រជុំប្រចាំខែ និងសម្ភារៈអនុវត្តការងាររបស់គណៈកម្មការសហគមន៍នេសាទ

| សកម្មភាព | លទ្ធផលរំពឹងទុក | ប៉ាន់ប្រមាណតម្លៃ(ដុល្លា) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ប្រជុំ | -របាយការណ៍លទ្ធផលសម្រេចបានក្នុងខែ<br>-មានផែនការណ៍អនុវត្តបន្ត | ៣៦០ | -គណៈកម្មការ<br>-ក្រុមល្បាត | ១៥/រៀងរាល់ខែ<br>រយៈពេល(៣ឆ្នាំ) | |
| ទិញសម្ភារៈការិយាល័យ | មានសម្ភារៈការិយាល័យសម្រាប់ប្រើប្រាស់ | ៩០ | គណៈកម្មការ | រយៈពេល(៣ឆ្នាំ) | |

## គ៧-ផែនការផ្សព្វផ្សាយ និងបណ្តុះបណ្តាល

ផែនការផ្សព្វផ្សាយ និងបណ្តុះបណ្តាលត្រូវបានរៀបចំឡើងដូចខាងក្រោម :

| សកម្មភាព | លទ្ធផលរំពឹងទុក | ប៉ាន់ប្រមាណតម្លៃ (ដុល្លា) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ផែនការផ្សព្វផ្សាយ | | | | | |
| ប្រជុំផ្សព្វផ្សាយអំពីច្បាប់ជលផល ឯកសារគតិយុត្តិនានាដែលពាក់ព័ន្ធនឹងសហគមន៍នេសាទ និងបទពិសោធន៍ដែលទទួលបាន | -សមាជិកសហគមន៍នេសាទ និងអ្នកខាងក្រៅមានការយល់ដឹង និងអនុវត្តតាម<br>-សមាជិកនិងប្រជាពលរដ្ឋចូលរួមអនុវត្តតាមផែនការ និងវិធានច្បាប់<br>-ផលត្រីនៅក្នុងសហគមន៍មានការកើនឡើងប្រជាពលរដ្ឋអាចរកត្រីបានច្រើននាំឲ្យជីវភាពធូរធារ | ៦៤៥ | គណៈកម្មការ,សមាជិកស.ននិងអ្នកក្រៅស.ន អាជ្ញាធរមូលដ្ឋាន ជំនាញជលផល, អង្គការដៃគូរ | មេសា/រៀងរាល់ឆ្នាំ (៣ឆ្នាំ) | |
| បិទផ្សាយឯកសារសហគមន៍១ដង/ឆ្នាំ | | ៣០ | | ខែមករា/ (រាល់ឆ្នាំ) | ខែមករា (រាល់ឆ្នាំ) |
| ចែកចាយឯកសារផែនការប្រើប្រាស់ឧបករណ៍ដល់អ្នកនេសាទ១ដង/ឆ្នាំ | | ៣០០ | | មិថុនា (រាល់ឆ្នាំ) | មិថុនា (រាល់ឆ្នាំ) |
| ផែនការបណ្តុះបណ្តាល | | | | | |
| វគ្គបណ្តុះបណ្តាលពីរបៀបរៀបចំលិខិតរដ្ឋបាល :<br>-របាយការណ៍<br>-កំណត់ហេតុ<br>-ភាពជាអ្នកដឹកនាំស.ន<br>-គម្រោងស្នើសុំថវិកា | គណៈសហគមន៍នេសាទ សមាជិកស.ន ប្រជាពលរដ្ឋ សិស្ស និស្សិតបានយល់ដឹង និងអាចអនុវត្តបាន ក្នុងការងារជាក់ស្តែង | ១ ៥០០ | គណៈកម្មការនិងសមាជិកស.ន អាជ្ញាធរមូលដ្ឋាន សិស្ស,និស្សិត | (ម្តង /ឆ្នាំ) មករា (រាល់ឆ្នាំ) | មករា (រាល់ឆ្នាំ) |

| | | | | | |
|---|---|---|---|---|---|
| -គម្រោងថវិកា និងគ្រប់គ្រងថវិកា | | | | | |
| វគ្គបណ្តុះបណ្តាលពីកំព្យូទ័រ | គណៈសហគមន៍នេសាទ(៣ នាក់) | ៣១៥ | គណៈសហគមន៍នេសាទ | ឧសភា-ធ្នូ/២០២០ | |

**គ៨-ផែនការវារីវប្បកម្ម**

**ផែនការអភិវឌ្ឍន៍វារីវប្បកម្មត្រូវបានរៀបចំឡើងដូចខាងក្រោមៈ**

| ប្រភេទវារីវប្បកម្ម | ចំនួន | ប្រភេទកូនត្រី | បរិមាណកូនត្រី | ខែ/ឆ្នាំ | |
|---|---|---|---|---|---|
| | | | | ចាប់ផ្តើម | ប្រមូលផល |
| កង្កែបក្នុងតង់/អាង | ៤០គ្រួសារ | ១០០០កូន/គ្រួសារ | ៤០ ០០០ | ចុងឆ្នាំ២០១៩ | ពាក់កណ្តាលឆ្នាំ២០២០ |
| អន្ទង់ក្នុងអាង/តង់ | ៤០គ្រួសារ | ៥គីឡូ/គ្រួសារ | ២០០ | ចុងឆ្នាំ២០១៩ | ពាក់កណ្តាលឆ្នាំ២០២០ |
| ត្រីអណ្តែងក្នុងអាង/តង់ | ២០គ្រួសារ | ៥គីឡូ/គ្រួសារ | ១០០ | ចុងឆ្នាំ២០១៩ | ពាក់កណ្តាលឆ្នាំ២០២០ |
| បង្កងក្នុងស្រែ | ៤គ្រួសារ | ៥គីឡូ/គ្រួសារ | ២០ | ចុងឆ្នាំ២០១៩ | ពាក់កណ្តាលឆ្នាំ២០២០ |

**គ៩-ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍសហគមន៍**

ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍសហគមន៍ត្រូវបានរៀបចំឡើងដូចខាងក្រោម :

| ប្រភេទប្រាក់ចំណូល | សកម្មភាព | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំចាប់បញ្ចប់ | ចំណូលដុល្លា | ផ្សេងៗ |
|---|---|---|---|---|---|
| ភាគទានសមាជិកភាពសហគមន៍នេសាទ | -ផ្សព្វផ្សាយជ្រើសរើសសមាជិក និងបង់ប្រាក់សមាជិកភាព<br>-ប្រមូលភាគទាន ៥០០រៀល/ម្នាក់ | តុលា/២០១៩ (រៀងរាល់ឆ្នាំ) | ខែធ្នូ /២០១៩ | ៣៨,២៥ | ៥០០រៀល/នាក់ (៣០៦នាក់) |
| ភាគទានប្រចាំឆ្នាំ | -ផ្សព្វផ្សាយជូនដំណឹងដល់សមាជិកបង់ប្រាក់ភាគទានប្រចាំឆ្នាំ<br>-ប្រមូលភាគទានប្រចាំឆ្នាំអ្នកនេសាទជាប្រចាំ ២.០០០០ រៀល/ម្នាក់ អ្នកនេសាទម្តងម្កាល ៥.០០០រៀល/នាក់ និង អ្នកមិននេសាទ១.០០០ រៀល/នាក់ | ខែមករា /២០២០ | ខែធ្នូ /២០២០ | ៦៦៧ | -ប្រចាំ៨៦នាក់ ២០.០០០ រៀល/នាក់<br>-ម្តងម្កាល១៨២ នាក់ ៥.០០០ រៀល/នាក់<br>-មិននេសាទ៣៨ នាក់ ១.០០០ រៀល/នាក់<br>(រយៈពេល៣ឆ្នាំ) |
| ប្រាក់ចំណូលពីអ្នក | -ផ្សព្វផ្សាយជូនដំណឹង | ជាប្រចាំ | | ១ ៧១៥ | ១៥.០០០រៀល/នាក់ |

| | | | | | |
|---|---|---|---|---|---|
| នេសាទមិនមែនជាសមាជិកបង់កម្រៃការធ្វើនេសាទ | -ដល់សមាជិកក្រៅស.ន បង់ប្រាក់កម្រៃធ្វើនេសាទ<br>-ធ្វើកិច្ចសន្យានិងប្រមូលកម្រៃនេសាទ | | | | ៤៥៧ទុករាល់ឆ្នាំ (រយៈពេល ៣ឆ្នាំ) |
| ប្រាក់ចំណូលបានពីការផាកពិន័យ | ធ្វើការផាកពិន័យដល់ជនល្មើសដែលទន្ទ្រានដី | រយៈពេល៣ឆ្នាំ | | ១៥០០ | |
| សរសេរគម្រោងស្នើសុំថវិកាពីរដ្ឋាភិបាល សប្បុរសជន និងអង្គការដៃគូរពាក់ព័ន្ធ | -ទំនាក់ទំនងជាមួយរដ្ឋាភិបាល និងអង្គការដៃគូរ<br>-សរសេរគម្រោងស្នើសុំថវិកា<br>-តាមដានដាក់បញ្ចូលផែនការប្រជុំជាមួយឃុំ | ២០១៩ | ២០២២ | ១៨១ ៨៤៣ | |
| សរុប | | | | ១៨១ ៨៤៣ | ដោយមិនបានបូលបញ្ចូលចំណូលពីសមាជិក ភាគទានវិការបង់កម្រៃរបស់អ្នកនេសាទ |

## ឃ. ផែនការយុទ្ធសាស្ត្រ

ដើម្បីអនុវត្តផែនការឱ្យទទួលបានជោគជ័យ យុទ្ធសាស្ត្រមួយចំនួនត្រូវបានរៀបចំដូចខាងក្រោម ៖

- បង្កើតគណៈកម្មការសម្រាប់អនុវត្តតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តផែនការ រួមមាន ៖ សមាជិកគណៈកម្មការសហគមន៍នេសាទចាស់ទុំ ដែលមានបទពិសោធន៍ និងចំណេះដឹងល្អៗ ជាពិសេសបញ្ហានេសាទ ។
- ស្នើសុំជំនួយបច្ចេកទេសពីរដ្ឋបាលជលផលមានសមត្ថកិច្ច ដើម្បីជួយផ្តល់យោបល់ចំពោះផែនការណាដែលទាក់ទង និងបច្ចេកទេសជលផល ដូចជា ការធ្វើផែនការកន្លែងអភិរក្សមេពូជត្រី ការរៀបចំកន្លែងអភិរក្សព្រៃលិចទឹក កន្លែងអភិរក្សជីវៈចម្រុះ ការស្តារព្រៃក ការកំណត់ឧបករណ៍នេសាទ ការចិញ្ចឹមត្រី ការរកថវិកាទ្រទ្រង់ជាដើម ។
- រៀបចំយុទ្ធសាស្ត្រទំនាក់ទំនងជាមួយស្ថាប័នជំនាញ អង្គការនានា គម្រោង និងម្ចាស់ជំនួយដើម្បីទទួលបានការ ឧបត្ថម្ភគាំទ្រ និងថវិការសម្រាប់ដំណើរការអនុវត្តផែនការ ។
- រៀបចំផែនការអនុវត្តផែនការតាមដំណាក់កាលនិមួយៗដោយជាក់លាក់និងផែនការសកម្មភាពប្រចាំឆ្នាំ
- ទាក់ទងជាមួយរដ្ឋបាលជលផលដើម្បីសុំការគាំទ្រថវិកា
  និងជួយរកដៃគូសម្រាប់ទ្រទ្រង់ផែនការគ្រប់គ្រង សហគមន៍នេសាទ ។

- ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ដល់សមាជិកសហគមន៍នេសាទនិងអ្នកពាក់ព័ន្ធសំខាន់ៗ ដើម្បីជម្រុញការចូលរួម និងគាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រងនេះ ។
- កៀងគរការចូលរួមចំណែករបស់សមាជិកសហគមន៍នេសាទ ។
- រៀបចំវិធានការចំពោះអ្នកនេសាទមកពីខាងក្រៅសហគមន៍ ។
- ពង្រឹងសម្ថភាពបច្ចេកទេស និងគ្រប់គ្រងរបស់គណៈកម្មការសហគមន៍នេសាទ ។
- ចងក្រងក្រុមអ្នកនេសាទទៅតាមប្រភេទឧបករណ៍នេសាទ ដើម្បីចូលរួមអនុវត្តផែនការ ។
- បញ្ចូលផែនការគ្រប់គ្រងសហគមន៍នេសាទទៅក្នុងផែនការអភិវឌ្ឍឃុំ ។
- រៀបចំធ្វើស្លាក់ការសហគមន៍នេសាទចំនួនមួយខ្នង និងទិញទូកម៉ាស៊ីនចំនួន១គ្រឿងសម្រាប់គ្រប់គ្រង និងថែរក្សា ការពារកន្លែងនេសាទសហគមន៍ ។

តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍អាងទឹកកែប្រែ រយៈពេល ៣ ឆ្នាំ ( ខែកក្កដា ឆ្នាំ២០១៩ ដល់ ខែមិថុនា ឆ្នាំ២០២២ )

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានចំណាយ | ប្រភពជំនួយ | ពេលផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| ១. ការប្រើប្រាស់ឧបករណ៍នេសាទ | ធ្វើនេសាទ | -ត្រីកើន<br>-បង្កើនប្រាក់ចំណូល | | សមាជិកនិងគណៈកម្មការ | ២០១៩ | ២០២២ | |
| ២.ការកែលំអកន្លែងនេសាទសហគមន៍ | -ប្រើគ្រឿងចក្រស្តារ<br>-ស្វែងរកម្ចាស់ជំនួយ<br>-ប្រជុំផ្សព្វផ្សាយ<br>-សាងសង់ទំនប់បង្ហារ | ត្រីកើន | ១៣០,៨២៥ | - ស.ន.ស.គ.យ.ម<br>- រាជរដ្ឋាភិបាល<br>- អង្គការនានា<br>- សប្បុរសជន | ២០១៩ | ២០២២ | |
| ៣.ការកំណត់ និងរៀបចំកន្លែងអភិរក្ស | -ផ្សព្វផ្សាយ<br>-បោះបង្គោល<br>-ដាក់ស្លាកសញ្ញា<br>-ការពារ<br>-លែងកូនត្រី<br>-ចងទ្រនំកំប្លោក | ត្រីកើនឡើងវិញ | ៥,៦៥៨ | -ស.ន.ស.គ.យ.ម<br>- រាជរដ្ឋាភិបាល<br>- អង្គការនានា<br>- សប្បុរសជន | ២០១៩ | ២០២២ | |
| ៤.ផែនការគ្រប់គ្រងព្រៃលិចទឹក | -ផ្សព្វផ្សាយ<br>-ដាំព្រៃលិចទឹក<br>-ការពារ<br>-បោះបង្គោល<br>-ដាក់ស្លាកសញ្ញា | -ព្រៃលិចទឹកកើន<br>-ត្រីកើន | ៧,២០០ | - ស.ន.ស.គ.យ.ម<br>- រាជរដ្ឋាភិបាល<br>- អង្គការនានា<br>- សប្បុរសជន | ២០១៩ | ២០២១ | |
| ៥.ផែនការទប់ស្កាត់បទល្មើសជលផល | -ប្រជុំផ្សព្វផ្សាយ<br>-ប្រជុំរៀបចំផែនការល្បាត<br>-ចុះអនុវត្តផែនការ | -ធនធានព្រៃលិចទឹកនិងជលផលកើនឡើង<br>-ប្រជាពលរដ្ឋមានជីវភាពធូរធារ | ៤,៩២០ | - ស.ន.ស.គ.យ.ម<br>- រាជរដ្ឋាភិបាល<br>- អង្គការនានា<br>- សប្បុរសជន | ២០១៩ | ២០២២ | |
| ៦. ផែនការប្រជុំប្រចាំខែ និងសម្ភារៈអនុវត្តការងាររបស់គណៈកម្មការ | -ប្រជុំ<br>-ទិញសម្ភារៈការិយាល័យ | -របាយការណ៍លទ្ធផលសម្រេចបាន ប្រចាំខែ<br>-មានសម្ភារៈការិយាល័យសម្រាប់ប្រើប្រាស់ | ៤៥០ | ស.ន.ស.គ.យ.ម | ២០១៩ | ២០២២ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៧. ផែនការផ្សព្វផ្សាយ និង បណ្តុះបណ្តាល | -ផ្សព្វផ្សាយ<br>-បិទផ្សាយឯកសារ<br>-ចែកឯកសារ | គណៈកម្មការនិងសមាជិកសហគមន៍នេសាទ និង ប្រជាពលរដ្ឋមានការយល់ដឹង | ២,៧៩០ | - ស.ន.ស.គ.ឃ.ម<br>- រាជរដ្ឋាភិបាល<br>- អង្គការនានា<br>- សប្បុរសជន | ២០១៩ | ២០២២ | |
| ៨.ផែនការវារីវប្បកម្ម | -បណ្តុះបណ្តាល<br>-រៀបចំអាង និងស្រះ<br>-លែងកូនពូជ<br>-ថែទាំ | -ជីវភាពសមាជិកធូរធារ<br>-កាត់បន្ថយការចំណាយ<br>-កាត់បន្ថយផលចាប់ក្នុងស្តុក | ៣០,០០០ | - រាជរដ្ឋាភិបាល<br>- អង្គការនានា | ២០១៩ | ២០២២ | |
| ៩.ផែនការថវិកាទ្រទ្រង់សហគមន៍នេសាទ | -ប្រមូលភាគទានសមាជិកភាព<br>- ភាគទានប្រចាំឆ្នាំ<br>- កម្រៃពីអ្នកខាងក្រៅ<br>- សរសេរគម្រោងស្នើសុំរាជរដ្ឋាភិបាល សិប្បុរសជន អង្គការនានា | មានថវិកាអនុវត្តសកម្មភាព | | - ស.ន.ស.គ.ឃ.ម<br>- រាជរដ្ឋាភិបាល<br>- អង្គការនានា<br>- សប្បុរសជន | ២០១៩ | ២០២២ | |
| សរុប | | | ១៨១ ៨៤៣ | | | | |

តារាងកម្មវិធីការងាររយៈពេល៣ឆ្នាំ ខែកក្កដា ២០១៩ ដល់ ខែមិថុនា២០២២

| សកម្មភាព | កាលបរិច្ឆេទ | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០១៩ | | | | | ២០២០ | | | | | ២០២១ | | | | | ២០២២ | | | | | |
| | កក្កដា | សីហា | កញ្ញា | ... | ធ្នូ | មករា | កុម្ភៈ | មីនា | ... | ធ្នូ | មករា | កុម្ភៈ | មីនា | .... | ធ្នូ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា |
| ១. ការប្រើប្រាស់ឧបករណ៍នេសាទ | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x |
| ២.ការកែលំអកន្លែងនេសាទសហគមន៍ | | | | | | x | x | x | | | | x | x | x | x | x | x | x | | | |
| ៣.ការកំណត់ និងរៀបចំកន្លែងអភិរក្ស | x | | | | | | x | x | x | x | | | x | x | | | x | x | x | x | |
| ៤.ផែនការគ្រប់គ្រងព្រៃលិចទឹក | | | | | | x | x | x | x | | x | x | x | x | x | x | x | x | x | x | x |
| ៥.ផែនការទប់ស្កាត់បទល្មើសជលផល | | | | x | | x | | x | | x | | x | x | x | x | x | x | x | | | |
| ៦.ផែនការប្រជុំប្រចាំខែនិងទិញសម្ភារៈការិយាល័យ | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x |
| ៧.ផែនការផ្សព្វផ្សាយ និងបណ្ដុះបណ្ដាល | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x |
| ៨.ផែនការវារីវប្បកម្ម | | x | x | x | x | x | x | x | | | | | | x | x | x | x | x | x | | |
| ៩.ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍសហគមន៍ | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x |